# សុន្ទរកថាបើក

**ឯកឧត្តម ថៅ សេដ្ឋាណា** អនុរដ្ឋលេខាធិការ និង ជាប្រធានក្រុមការងារបច្ចេកទេសវិមជ្ឈការ និង វិសហមជ្ឈការ ក្រសួងមុខងារសាធារណៈ ក្នុងពិធីបើក "សិក្ខាសាលាស្តីពីការចាប់ផ្តើមការសិក្សាលើ មុខងារ រចនាសម្ព័ន្ធ និងនីតិវិធីនៃការបំពេញការងាររបស់អង្គភាពធនធានមនុស្សនៅថ្នាក់ក្រោមជាតិ"
រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦

*ឯកឧត្តម លោកជំទាវ គណៈអធិបតី*

- *លោកស្រី Maraile Goergen ប្រធាន កម្មវិធីកំណែទម្រង់វិមជ្ឈការ និងរដ្ឋបាលនៃអង្គការ GIZ*
- *លោក លោកស្រីតំណាងកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់-GIZ*
- *លោក លោកស្រីដែលជាមន្ត្រីបង្គោលរបស់ក្រសួង ស្ថាប័ន*
- *ឯកឧត្តម លោកជំទាវ លោក លោកស្រីជាសហការីនៃក្រសួងមុខងារសាធារណៈ*
- *អង្គពិធីទាំងមូលជាទីមេត្រី*

ថ្ងៃនេះ ខ្ញុំពិតជាមានក្តីសោមនស្សរីករាយដែលបានចូលរួមជាអធិបតីភាពក្នុងពិធីបើក**"អង្គសិក្ខាសាលាស្តីពីការចាប់ផ្តើមការសិក្សាលើមុខងារ រចនាសម្ព័ន្ធ និងនីតិវិធីនៃការបំពេញការងាររបស់អង្គភាពធនធានមនុស្សនៅថ្នាក់ក្រោមជាតិ"** ដោយទទួលការរៀបចំផ្នែកហិរញ្ញវត្ថុដោយកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់-GIZ។

ឆ្លៀតក្នុងឱកាសដ៏ល្អប្រសើរនេះ ក្នុងនាមក្រសួងមុខងារសាធារណៈនិងក្រុមការងារ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះដៃគូអភិវឌ្ឍន៍-GIZ ដែលតែងតែផ្តោតការយកចិត្តទុកដាក់សហការ និងជួយឧបត្ថម្ភគាំទ្រដល់ការងារអាទិភាពសំខាន់ៗដែលពាក់ព័ន្ធនឹងការកែទម្រង់រដ្ឋបាលសាធារណៈ ទាំងក្នុងពេលកន្លងមក ក៏ដូចជាបច្ចុប្បន្ន។

***ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាង កញ្ញា និងអង្គពិធីទាំងមូលជាទីមេត្រី***

ក្នុងក្របខណ្ឌនៃការជំរុញអនុវត្តកំណែទម្រង់រដ្ឋបាលសាធារណៈ រាជរដ្ឋាភិបាលកម្ពុជាក្នុងនីតិកាលទី៥នៃរដ្ឋសភា ដូចដែលបានគូសបញ្ជាក់ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ បានដាក់ចេញនូវចក្ខុវិស័យច្បាស់លាស់គឺ **ការកសាងរដ្ឋបាលសាធារណៈឱ្យកាន់តែមានភាពឆ្លើយតប មានប្រសិទ្ធភាព ប្រសិទ្ធផល និងជំនឿទុកចិត្ត ព្រមទាំងលើកកម្ពស់វប្បធម៌សេវាសាធារណៈ ឆន្ទៈម្ចាស់ការ ភក្តីភាព និងមនសិការវិជ្ជាជីវៈ របស់មន្ត្រីរាជការ ដើម្បីប្រែក្លាយរដ្ឋបាលសាធារណៈ ឱ្យទៅជាអ្នកផ្តល់សេវាសាធារណៈដ៏មានប្រសិទ្ធភាព ក្នុងគោលដៅរួមគឺ បម្រើប្រជាជនឱ្យបានកាន់តែល្អប្រសើរឡើង។** ក្នុងស្មារតីនេះ រាជ-រដ្ឋាភិបាលនឹងបន្តផ្តោតលើការអនុវត្តយុទ្ធសាស្ត្រសំខាន់ៗបី ក្នុងក្របខណ្ឌនៃកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈគឺ ៖

**យុទ្ធសាស្ត្រទី១-ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ** តាមរយៈការបង្កើត និងដាក់ឱ្យអនុវត្តស្តង់ដារសេវាសាធារណៈដែលមានសូចនាករសំខាន់ៗប្រាំគឺ ១-គុណភាពព័ត៌មាន ២-ភាពងាយស្រួលក្នុងការទទួលយកសេវា ៣-ភាពយកចិត្តទុកដាក់ក្នុងការទទួលអ្នកប្រើប្រាស់សេវា ៤-សេវាផ្តល់តាមគោលការណ៍កំណត់និងមានអភិបាលកិច្ចល្អ និង ៥-យន្តការទទួលព័ត៌មានត្រឡប់និងបណ្តឹងរបស់អ្នកប្រើប្រាស់សេវា។

**យុទ្ធសាស្ត្រទី២-ការអភិវឌ្ឍសមត្ថភាព ការកែលម្អការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស** តាមរយៈការជំរុញអនុវត្តគោលនយោបាយធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ ពិសេសការបន្តពង្រឹងការគ្រប់គ្រងនិងការចាត់ចែងការងារ ការកែលម្អការគ្រប់គ្រងជំនាញនិងចំនួនមន្ត្រី ការពង្រឹងសមត្ថភាពការងារ សីលធ៌មនិងវិន័យរបស់មន្ត្រី ព្រមទាំងការរៀបចំផែនការធនធានមនុស្ស និងការបន្តវេន និង

**យុទ្ធសាស្ត្រទី៣-ការកែទម្រង់ប្រព័ន្ធបៀវត្ស និងប្រាក់បន្ថែមផ្សេងៗ** ដោយឈរលើគោលការណ៍សំខាន់ៗរួមមាន៖ ការដំឡើងបៀវត្សស្របតាមស្ថានភាពនៃកំណើនសេដ្ឋកិច្ច និងលទ្ធភាពទ្រទ្រង់បាននៃថវិកាជាតិ ការធានាបាននូវសមធម៌ ការបង្កើនផលិតភាព និងប្រសិទ្ធភាពការងារ និងការធានាសង្គតិភាពរវាងក្របខណ្ឌមន្ត្រីរាជការស៊ីវិល និងក្របខណ្ឌកងកម្លាំងប្រដាប់អាវុធ។

នៅក្នុងបរិការនៃសកលភាវូបនីយកម្ម និងការប្រកួតប្រជែងលើឆាកអន្តរជាតិ រាជរដ្ឋាភិបាលបានចាត់ទុកការធ្វើកំណែទម្រង់រដ្ឋបាលសាធារណៈ ជាការងារអាទិភាពមួយក្នុងចំណោមការងារអាទិភាពនានារបស់រាជរដ្ឋាភិបាល ដែលតម្រូវឱ្យលើកកម្ពស់ប្រសិទ្ធភាពការងារ និងបង្កើនសមត្ថភាពរដ្ឋបាលសាធារណៈឱ្យកាន់តែមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីឆ្លើយតបទៅនឹងបរិការខាងលើបានទាន់ពេលវេលា។ នៅក្នុងន័យនេះ ការពង្រឹងនិងការកែលម្អដំណើរការនៃការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស សំដៅប្រែក្លាយធនធានមនុស្សនៅក្នុងវិស័យសាធារណៈ ឱ្យកាន់តែមានសមត្ថភាព មានវិជ្ជាជីវៈច្បាស់លាស់ និងមានប្រសិទ្ធភាពក្នុងការបំពេញការងារ គឺជាកិច្ចការគន្លឹះ និងមានសារៈសំខាន់បំផុត។

ដើម្បីសម្រេចបានគោលបំណងខាងលើនេះ ក៏ដូចជាដើម្បីធានានូវភាពជោគជ័យក្នុងការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈឆ្នាំ២០១៥-២០១៨ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរយៈពេល១០ឆ្នាំ២០១០-២០១៩ គោលនយោបាយធនធានមនុស្សក្នុងរដ្ឋ-បាលសាធារណៈ គោលនយោបាយស្តីពីការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោម-ជាតិ និងជាពិសេសដើម្បីរៀបចំបទដ្ឋានគតិយុត្តសម្រាប់គាំទ្រដល់ការអនុវត្តព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរាជរដ្ឋាភិបាលបានអនុម័តនាពេលកន្លងមក ការចូលរួមពីគ្រប់ក្រសួង ស្ថាប័ន មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ កិច្ចសហការនិងការគាំទ្រពីដៃគូអភិវឌ្ឍន៍ គឺជាកត្តាចាំបាច់ និងមិនអាចខ្វះបាន។ ក្នុងបរិបទនេះ ការសិក្សាអំពីស្ថានភាពជាក់ស្តែងស្តីពីមុខងារ រចនាសម្ព័ន្ធ និងនីតិវិធីបំពេញការងាររបស់អង្គភាពធនធានមនុស្សនៅថ្នាក់ក្រោមជាតិ គឺជាការចាំបាច់បំផុត។

***ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាង កញ្ញា និងអង្គពិធីទាំងមូលជាទីមេត្រី***

គោលបំណងនៃអង្គសិក្ខាសាលានេះមានគោលបំណងធំៗគឺ (១)ផ្តល់ឱកាសដល់រដ្ឋបាលថ្នាក់ក្រោមជាតិនិងមន្ទីរជំនាញនានាដើម្បីពង្រឹងសមត្ថភាពផ្ទាល់ខ្លួនក្នុងការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សក្នុងស្ថាប័នសាមី (២)កំណត់ពង្រឹងតួនាទីរបស់អង្គភាពគ្រប់គ្រងធនធានមនុស្សនៅថ្នាក់ក្រោមជាតិក្នុងការ

គ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សនៅថ្នាក់ក្រោមជាតិ និង (៣)ផ្តល់នូវជម្រើសជាយុទ្ធសាស្ត្រនានា ដើម្បីគាំទ្រដល់ការអនុវត្តបទដ្ឋានគតិយុត្តក្នុងការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សនៅថ្នាក់ក្រោមជាតិ។

អង្គភាពធនធានមនុស្ស គឺជាអង្គភាពស្នូលរបស់អង្គភាពថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្ស។ ជាការពិតណាស់អង្គភាពធនធានមនុស្សមានភារកិច្ចសំខាន់ក្នុងការរៀបចំ និងការដាក់ឲ្យអនុវត្តផែនការធនធានមនុស្ស ការជ្រើសរើសមន្ត្រីរាជការ ការរៀបចំការឡើងថ្នាក់ ឋានន្តរស័ក្តិ ការតែងតាំងក្នុងមុខតំណែង ការបណ្តុះបណ្តាលនិងការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ ការគ្រប់គ្រងគុណផលការងារមន្ត្រីរាជការ ដោយរួមមានទាំងការរៀបចំការពិពណ៌នាមុខតំណែងនីមួយៗ ជាដើម។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា បន្ទាប់ពីសិក្ខាសាលាក្នុងរយៈពេលមួយថ្ងៃនេះបានបញ្ចប់ ដោយឆ្លងកាត់តាមរយៈការធ្វើបទបង្ហាញរបស់មន្ត្រីជំនាញនៃក្រសួងមុខងារសាធារណៈនិងអ្នកជំនាញការជាតិរបស់GIZ និងការពិភាក្សាតាមក្រុមដែលមានចូលរួមពីសំណាក់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញា ដែលអញ្ជើញមកពីក្រសួង ស្ថាប័នចំនួន៥ យើងនឹងទទួលបាននូវការគាំទ្រពីអ្នកពាក់ព័ន្ធទាំងអស់លើការអនុវត្តការសិក្សា ស្តីពីមុខងារ រចនាសម្ព័ន្ធ និងនីតិវិធីនៃការបំពេញការងាររបស់អង្គភាពធនធានមនុស្សនៅថ្នាក់ក្រោមជាតិ ប្រមូលបានធាតុចូលសម្រាប់កំណត់វិធីសាស្ត្រនិងវិសាលភាពនៃការសិក្សាប្រមូលព័ត៌មានស្តីពីការបំពេញមុខងារគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានមនុស្សនៅថ្នាក់ក្រោមជាតិ និងទទួលបាននូវផែនការសកម្មភាពសម្រាប់ជំហានបន្ទាប់។

ជាថ្មីម្តងទៀត ក្នុងនាមក្រសួងមុខងារសាធារណៈ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណចំពោះវត្តមានរបស់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាង កញ្ញាទាំងអស់ក្នុងអង្គពិធីបើក **"អង្គសិក្ខាសាលាស្តីពីការចាប់ផ្តើមការសិក្សាលើមុខងារ រចនាសម្ព័ន្ធ និងនីតិវិធីនៃការបំពេញការងាររបស់អង្គភាពធនធានមនុស្សនៅថ្នាក់ក្រោមជាតិ"** និងសូមអរគុណផងដែរចំពោះការគាំទ្រផ្នែកហិរញ្ញវត្ថុរបស់កិច្ចសហប្រតិបត្តិការអាល្លឺម៉ង់-GIZ។

ខ្ញុំសូមជូនពរដល់ដំណើរការនៃអង្គសិក្ខាសាលានេះ ប្រព្រឹត្តទៅប្រកបដោយផ្លែផ្កា និងទទួលបានជោគជ័យ និងសូមជូនពរ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ សូមប្រកបដោយពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ខ្ញុំសូមប្រកាសបើក"អង្គសិក្ខាសាលាស្តីពីការចាប់ផ្តើមការសិក្សាលើមុខងារ រចនាសម្ព័ន្ធ និងនីតិវិធីនៃការបំពេញការងាររបស់អង្គភាពធនធានមនុស្សនៅថ្នាក់ក្រោមជាតិ" ចាប់ពីពេលនេះតទៅ។

សូមអរគុណ!